ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០៩......១៩.អស.រ.សសិលា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

ថ្ងៃព្រហស្បតិ៍ ៦រោច ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសបេក្ខជនទៅចូលរួមវគ្គបណ្តុះបណ្តាលខ្លីនៅប្រទេសចិន ស្តីពីបច្ចេកទេសគ្រប់គ្រងដំណើរការមន្ទីរពិសោធន៍ភូគព្ភសាស្ត្រជាតិកម្ពុជា

ក្រសួងរ៉ែនិងថាមពល សូមជូនដំណឹងដល់មន្ត្រីរាជការក្រោមឱវាទក្រសួង និស្សិត និងសាធារណៈជនទាំងអស់មេត្តាជ្រាបថា ក្រសួងត្រូវការជ្រើសរើសបេក្ខជន ចំនួន០៩រូប ដើម្បីទទួលការបណ្តុះបណ្តាលស្តីពីបច្ចេកទេសគ្រប់គ្រងដំណើរការមន្ទីរពិសោធន៍ភូគព្ភសាស្ត្រជាតិកម្ពុជា នៅសាធារណៈរដ្ឋប្រជាមានិតចិន។ ក្រោយពេលចប់ការបណ្តុះបណ្តាលនឹងត្រូវចាត់ឱ្យទៅបំពេញការងារនៅមន្ទីរពិសោធន៍ខាងលើ។

ព័ត៌មាននៃការបណ្តុះបណ្តាល លក្ខខណ្ឌជ្រើសរើស និងការដាក់ពាក្យដូចខាងក្រោម៖

១. ព័ត៌មានអំពីការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលមានរយៈពេល០៥ខែ ដែលនឹងចាប់ផ្តើមពីខែតុលា ឆ្នាំ២០១៩
- ការចំណាយលើថ្លៃសិក្សា ការហូបចុក ការស្នាក់នៅ ការធានារ៉ាប់រងសុខភាព និងសំបុត្រយន្តហោះជាបន្ទុករបស់ភាគីចិន។ ក្រសួងនឹងផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមជារៀងរាល់ខែ ចំនួន១លានរៀល រយៈពេល០៥ខែ ក្នុងពេលនៃការបណ្តុះបណ្តាល។

២. លក្ខខណ្ឌនៃការជ្រើសរើស និងការដាក់ពាក្យ

- មានអាយុចាប់ពី ២០ឆ្នាំ រហូតដល់ ៣៦ឆ្នាំ
- មានបរិញ្ញាបត្ររងឡើងទៅ លើមុខជំនាញភូគព្ភសាស្ត្រ គីមីអាហារ ឬសញ្ញាបត្រសមមូល
- មានចំណេះដឹងមូលដ្ឋាន និងបទពិសោធន៍ផ្នែកការងារមន្ទីរពិសោធន៍ភូគព្ភសាស្ត្រជាពិសេសជំនាញគីមីភូគព្ភសាស្ត្រ (Geochemistry)
- អាចប្រើប្រាស់ភាសាអង់គ្លេស ឬចិនបានល្អ
- បេក្ខជនអាចទាញយកពាក្យស្នើសុំ កិច្ចសន្យា និងប្រវត្តិរូបពីគេហទំព័រ www.mme.gov.kh រួចយកមកដាក់នៅនាយកដ្ឋានភូគព្ភសាស្ត្រ-រ៉ែ ជាន់ទី៥ អគារទីស្តីការក្រសួងរ៉ែនិងថាមពល ឬផ្ញើតាមអ៊ីម៉ែល geology.cambodia@gmail.com ឱ្យបានមុនថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩។

**ត.ប. រដ្ឋមន្ត្រី**
**អគ្គនាយករងទទួលបន្ទុកស្តីទីរួម**
**អគ្គនាយកដ្ឋានកិច្ចការទូទៅ**

ឆែ_លីឌីន

សូមទំនាក់ទំនង:

- លោក ឈួន សម្បត្តិរតនៈ ០៩២ ៨០០ ៨៩៣
- លោក មាស បញ្ញា ០១៧ ៨២៨ ៤១៤